**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ជ.ស.ដ )
ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះសាលាដំបូង
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

---

**<u>ដាក់ដោយ</u>៖**

**ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE
លោក Andrew IANUZZI
លោក Jasper PAUW
លោក ព្រំ ផល្លា
សាស្ត្រាចារ្យ Michiel RAMSEDEN

**<u>ផ្ញើជូន</u>៖**

**ក្រុមមេធាវីការពារក្តីទាំងអស់**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក William SMITH

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ[1] មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("មេធាវីការពារក្តី") សូមដាក់ចម្លើយតបនេះទៅនឹងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវ ស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ("លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនង")[2]។ មេធាវីការពារក្តីនឹងលើកទឡ្ហីករណ៍ថា លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនង គួរត្រូវបានរក្សាទុក ពីព្រោះវាគឺជាលក្ខខណ្ឌតម្រូវមួយក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលវេលាដែលពាក់ព័ន្ធ។ លើសពីនេះទៀត មេធាវីការពារក្តីនឹងលើកអំណះអំណាងមួយចំនួនរបស់ ក.ស.ព ទាក់ទិននឹងគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*)។

## II. ប្រវត្តិនីតិវិធីពាក់ព័ន្ធ

២. ដើម្បីឱ្យចម្លើយតបនេះកាន់តែខ្លី មេធាវីការពារក្តីយោងទៅលើសំណើរបស់ ក.ស.ព ដើម្បីពិនិត្យមើលប្រវត្តិនីតិវិធីពាក់ព័ន្ធ[3]។

## III. ច្បាប់ពាក់ព័ន្ធ

៣. យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា "វិមតិសង្ស័យ [...] ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ មាត្រា២២(២) នៃលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចែងអំពីការការពារស្រដៀងគ្នានេះដែរថា៖ "និយមន័យនៃបទល្មើសព្រហ្មទណ្ឌត្រូវតែបកស្រាយអធិប្បាយឱ្យល្អិត ហើយមិនត្រូវពង្រីកវិសាលភាពដោយការពន្យល់ប្រៀបធៀបឡើយ។ នៅក្នុងករណីមានវិមតិសង្ស័យ ការកំណត់និយមន័យនោះ ត្រូវបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងត្រូវរងការស៊ើបអង្កេត ត្រូវនាំយកមកជំនុំជម្រះ ឬត្រូវបានសម្រេចឱ្យមានពិរុទ្ធភាព"។ ទាក់ទិននឹងបញ្ហានេះ នាពេលថ្មីៗ

---

[1] *មើល*ឯកសារលេខ E107, ឯកសារសាធារណៈ: "សេចក្តីសម្រេចលើសំណើសុំពន្យារពេល" ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១, ERN 00711953–00711954។

[2] ឯកសារលេខ No. E95 "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១, លេខ ERN 00705887-00705901, ("សំណើរបស់ ក.ស.ព") ។

[3] សំណើរបស់ ក.ស.ព, កថាខណ្ឌ ១-៥។

អង្គជំនុំជម្រះតុលាការកំពូលរបស់ អ.វ.ត.ក នេះបានសម្រេចថា "ចំពោះគោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អាចអនុវត្តបានចំពោះស្ថានភាពលំបាកនៃអត្ថន័យច្បាប់ គោលការណ៍នេះ ត្រូវកម្រិតត្រឹមតែភាពមន្ទិលសង្ស័យដែលមានក្រោយការបកស្រាយ"[4]។

## IV. ឧទ្ធីករណ៍

### ក. លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងគ្នាជាមួយជម្លោះប្រដាប់អាវុធមានអត្ថិភាព ក្នុងអំឡុងរយៈពេលដែលពាក់ព័ន្ធ

៤. មេធាវីការពារក្តីសន្និដ្ឋានថា លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងគ្នា មានអត្ថិភាពនៅក្នុងអំឡុងចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ ("របបកម្ពុជាប្រជាធិបតេយ្យ")។ ដើម្បីគាំទ្រការលើកឡើងនេះ (និងដើម្បីឱ្យចម្លើយបតនេះកាន់តែខ្លី) មេធាវីការពារក្តីយោងអំណះអំណាងរបស់ក្រុមមេធាវីការពារក្តី អៀង សារី និងក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ក្នុងបណ្តឹងឧទ្ធរណ៍នីមួយៗរបស់ពួកគាត់ប្រឆាំងនឹងដីកាដំណោះស្រាយ[5]។ អាស្រ័យហេតុនេះ យោងតាមទឡ្ហីករណ៍នានាដែលបានលើកសំណើរបស់ ក.ស.ព ត្រូវបដិសេធចោល។

### ខ. អង្គជំនុំជម្រះ គួរអនុវត្តតាមសំអាងហេតុ និងសេចក្តីសន្និដ្ឋានរបស់ អ.ប.ជ

៥. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង ច្រានចោលអំណះអំណាងរបស់មេធាវីការពារក្តីស្តីពីអត្ថិភាពនៃលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងគ្នាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះសាលាដំបូង គួរតែអនុវត្តតាមសំអាងហេតុ និងសេចក្តីសន្និដ្ឋានរបស់ អ.ប.ជ ក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[6] ។ ហេតុដូច្នេះ អ.ជ.ស.ដ គួរតែយល់ស្របនឹង

---

[4] ឯកសារលេខ No. E50/3/1/4, "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់", ERN 00702763-00702786 "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល" កថាខណ្ឌ ១៣។

[5] *មើល* ឯកសារ No **D427/1/6** "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ", ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០, ERN 00617486–00617631, កថាខណ្ឌ ១៨៨-១៨៩, ឯកសារលេខ D427/2/1, "បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ", ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, ERN 00613874–00613905, កថាខណ្ឌ ៦០ - ៦៣, *មើលផងដែរ* សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីពាក់ព័ន្ធ នៅក្នុងចម្លើយតប។

[6] *មើលឧទាហរណ៍* ឯកសារលេខ **D427/2/15,** ឯកសារសាធារណៈ, "សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ("សាលដីការបស់ អ.ប.ជ), កថាខណ្ឌ ១៣៤-១៤៥។

អ.ប.ជ ថាវាចាំបាច់ត្រូវសន្មតថា លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនង នៅតែមានអត្ថិភាព ពីព្រោះ គេមិនអាចបង្ហាញឱ្យឃើញថាលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនង ត្រូវបានដកចេញក្នុងអំឡុងពេល ដែលពាក់ព័ន្ធឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង ត្រូវសម្រេចថាទំនាក់ទំនងនឹង ជម្លោះប្រដាប់អាវុធ ត្រូវតែបានចោទ និងបង្ហាញឱ្យឃើញនៅចំពោះមុខ អ.វ.ត.ក ទាក់ទិននឹង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

៦. ក្នុងការវាយតម្លៃអំពីអត្ថិភាពនៃលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងគ្នា អ.ប.ជ សម្រេចថា៖

> សរុបមក ក្នុងករណីមិនមានការអនុវត្តច្បាស់លាស់របស់រដ្ឋនានា និងទស្សនៈច្បាប់ *(opinio juris)* ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលបង្ហាញឱ្យឃើញពីការផ្ដាច់ចេញនូវលក្ខខណ្ឌតម្រូវ នៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់ អន្តរជាតិនោះ គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* *(in dubio pro reo)* អះអាងថាភាពមិនច្បាស់លាស់ត្រូវតែដោះស្រាយដោយផ្ដល់ប្រយោជន៍ដល់ជនជាប់ចោទ[7]។

ក.ស.ព ជំទាស់យ៉ាងខ្លាំងចំពោះការលើកឡើងរបស់ អ.ប.ជ អំពីគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*ថា "ដោយអនុលោមតាមទម្ងន់នៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ គោលការណ៍ស្ដីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* បានផ្ដល់នូវផលប្រយោជន៍នៃការសង្ស័យដល់ជនជាប់ចោទ កាលណាមានភាពមិនច្បាស់លាស់អំពីថាតើភស្តុតាងនោះមានលក្ខណៈគ្រប់គ្រាន់ដែរឬទេ ដើម្បីគាំទ្រដល់ការកាត់សេចក្ដីមួយ[8]"។ ហេតុដូច្នេះ យោងតាម ក.ស.ព គោលការណ៍នេះ "មិនអាចប្រើប្រាស់ធ្វើជាមូលដ្ឋានមួយក្នុងការដោះស្រាយជម្លោះនានាស្ដីពីបញ្ហាច្បាប់សុទ្ធសាធនោះឡើយ ជាពិសេសជម្លោះនានាស្ដីពីការបកស្រាយច្បាប់តាមទំនៀមទម្លាប់អន្តរជាតិឱ្យបានត្រឹមត្រូវ"[9]។

៧. មេធាវីការពារក្ដី សូមសន្និដ្ឋានជាបឋមថា សេចក្ដីសម្រេចរបស់ អ.ប.ជ មិនមានអានុភាពចំពោះ ឬស្របទៅនឹងអំណះអំណាងស្ដីអំពីគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*ឡើយ។ កថាខណ្ឌដែលបានដកស្រង់ខាងលើនេះ បង្ហាញថា អ.ប.ជ *មិនអាចបង្ហាញអំពី*

---

[7] សាលដីការបស់ អ.ប.ជ, កថាខណ្ឌ ១៤៥។

[8] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៧។

[9] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៧។

ការអនុវត្តច្បាស់លាស់របស់រដ្ឋនានា និង *ទស្សនៈច្បាប់* (*opinio juris*) ស្តីពីការផ្តាច់ចេញលក្ខខណ្ឌតម្រូវឲ្យមានចំណងទាក់ទងឡើយ (ដែលតម្រូវឲ្យមានសំអាងហេតុ ដើម្បីពិចារណាលើ "ទស្សនៈនៃការផ្តាច់ចេញ"នេះ ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។ សេចក្តីសន្និដ្ឋាននេះ មានភាពត្រឹមត្រូវ ទោះជាមានការលើកឡើង ឬមិនមានការលើកឡើងអំពីគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*ក៏ដោយ។ ផ្អែកលើហេតុផលមួយនេះ សេចក្តីសម្រេចរបស់ អ.ប.ជ គួរតែត្រូវបានគោរព។

៨. ប៉ុន្តែដើម្បីជាការគាំទ្រដល់ទឡ្ហីករណ៍ ប្រសិនបើយើងសន្មតថា ការបកស្រាយសមស្របចំពោះគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មានភាពជាប់ទាក់ទងទៅនឹងសវនាការនេះ អំណះអំណាងលើកឡើងដោយ ក.ស.ព នៅតែត្រូវបានច្រានចោលដដែល។

៩. ជាបឋម មេធាវីការពារក្តី សូមសន្និដ្ឋានថា ការបកស្រាយន័យចង្អៀតចំពោះគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលលើកឡើងដោយ ក.ស.ព មានភាពខុសគ្នាពីសំអាងហេតុនាពេលថ្មីៗនេះរបស់អង្គជំនុំជម្រះតុលាការកំពូល។ អង្គជំនុំជម្រះតុលាការកំពូល ទទួលស្គាល់យ៉ាងច្បាស់ថាគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ក៏អាចដាក់បញ្ចូលក្នុង "ស្ថានភាពលំបាកនៃអត្ថន័យច្បាប់" ផងដែរ[10]។ អាស្រ័យហេតុនេះ ក្នុងនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គោលការណ៍នោះ គួរតែត្រូវបានយល់ក្នុងន័យទូលាយ។ ជាក់ស្តែង ចៅក្រម Jean-Marc Lavergne នៃអង្គជំនុំជម្រះសាលាដំបូង ទទួលស្គាល់ដូចគ្នានេះដែរ នៅក្នុងមតិជំទាស់របស់លោកនៅក្នុងសាលក្រមលើរឿងក្តីឌុច[11]។

---

[10] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៣១ (ទោះបីស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួន)។ *កំណត់សម្គាល់* ៖ គោលការណ៍ទូទៅអំពីការគោរពឋានានុក្រមផ្នែកតុលាការតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងគោរពតាមការបកស្រាយទូលំទូលាយរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងគោលការណ៍ស្តីពី *វិមតិសង្ស័យ*។

[11] *មើល* ឯកសារលេខ **E188,** ឯកសារធាធារណៈ, "សាលក្រម" ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ERN 00572517–00572797, ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ឌុច") "មតិជំទាស់របស់ចៅក្រម Jean-Marc Lavergne ពាក់ព័ន្ធនឹងការកំណត់ទោស ("មតិជំទាស់របស់ចៅក្រម Lavergne") កថាខណ្ឌ ៨ (បញ្ជាក់ថា នៅពេលច្បាប់មិនមានភាពច្បាស់លាស់ ឬមិនមានចែង ពេលនោះគេត្រូវប្រកាន់យកនូវដំណោះស្រាយដែលផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ នៅពេលមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តវិធានការដាក់លាក់ណាមួយនោះ" ដោយធ្វើការកត់សម្គាល់ថា "គោលការណ៍ដែលគេទទួលស្គាល់ជាទូទៅដែលបានចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" និងបញ្ជាក់ពីយុត្តិសាស្ត្រឧក្រិដ្ឋកម្មចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពី ទំនាក់ទំនងនៃជម្លោះ

១០. ប្រសិនបើយើងពិចារណាលើនិយមន័យនៃគោលការណ៍ ក្នុងដំណើរការនីតិវិធីច្បាប់*អន្តរជាតិ*នោះ មេធាវីការពារក្តី សូមលើកឡើងថា មិនមាននិយមន័យជាផ្លូវការណាមួយកំណត់គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*ឡើយ។ ដូច្នេះហើយ ការបកស្រាយទាំងន័យទូលាយ និងទាំងន័យចង្អៀត អាចត្រូវទទួលយកបាន[12] ។ ទោះបីយ៉ាងណា មេធាវីការពារក្តី សន្និដ្ឋានថា និយមន័យ និងវិសាលភាពជាក់លាក់នៃគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ក្នុងដំណើរការនីតិវិធីច្បាប់*អន្តរជាតិ* មិនមានភាពជាប់ទាក់ទងឡើយ។ នេះជាការត្រឹមត្រូវ ពីព្រោះមានគោលការណ៍ជាមូលដ្ឋានគ្រឹះមួយក្នុង*ច្បាប់កម្ពុជា* ដែលមានចែងក្នុងមាត្រាទី៣៨ នៃរដ្ឋធម្មនុញ្ញ ថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ[13]"។ ដូច្នេះ ពាក្យពេចន៍នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានន័យទូលាយ និងមានន័យច្បាស់លាស់៖ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ នេះសំដៅទៅលើវិមតិសង្ស័យចំពោះពិរុទ្ធភាព និងវិមតិសង្ស័យទាក់ទងនឹងភាពមិនច្បាស់លាស់នានានៅក្នុងច្បាប់។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ផ្តល់ការការពារជាចម្បងដល់សិទ្ធិជនជាប់ចោទ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ត្រូវធ្វើសេចក្តីសន្និដ្ឋានថា គោលការណ៍ដែលមានចែងក្នុងមាត្រា៣៨ គួរតែផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ ក្នុងករណីមានវិមតិសង្ស័យ។ អាស្រ័យហេតុនេះ វិធីសាស្ត្ររបស់ អ.ប.ជ គួរតែត្រូវបានរក្សាទុក[14]។

---

អន្តរជាតិដែលមានសេចក្តីសំអាងដូចតទៅ។ "គោលការណ៍ដែលថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ មិនមែនអនុវត្តតែចំពោះការវាយតម្លៃភស្តុតាងទាក់ទងនឹងការដាក់ពិរុទ្ធភាពជនជាប់ចោទ, ការអនុវត្តទូលំទូលាយ ប៉ុណ្ណោះទេ តែរួមទាំងការបកស្រាយបទដ្ឋានច្បាប់ជាធរមានដែលមានភាពស្រពិចស្រពិល ឬមានន័យមិនច្បាស់លាស់ទៀតផង")។

[12] *មើលខ្លឹមសារ ឧទាហរណ៍ ដូចខាងលើ។*

[13] ឯកសារជាភាសាបារាំងចែងថា "Le bénéfice du doute profite à l'accusé"។ បើទោះបីការប្រើប្រាស់ពាក្យនេះមិនសូវសង្កត់ធ្ងន់លើវិមតិសង្ស័យ "ណាមួយ" ក៏ដោយនៅពេលប្រៀបធៀបជាមួយនឹងឯកសារជាភាសាអង់គ្លេស, ឯកសារជាភាសាបារាំងនៅតែផ្តល់ការការពារ *មិនសមស្រប* ដល់ជនសង្ស័យ។

[14] នៅពេលពិនិត្យលើព្រឹត្តិការណ៍អតីតកាល, វាប្រហែលជាមានភាពប្រសើរជាង ប្រសិនបើអង្គបុរេជំនុំជម្រះមិនបានប្រើប្រាស់ឃ្លាដែលមានអត្ថន័យមិនច្បាស់លាស់ "*in dubio pro reo*" ក្នុងការផ្តល់សំអាងហេតុរបស់ខ្លួន។ ប្រហែលជា អង្គបុរេជំនុំជម្រះគួរបានធ្វើការសំអាងលើគោលការណ៍ដែលបានកំណត់ជាស្រេចដែលមាននៅក្នុងមាត្រា ៣៨នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា។ វិធីសាស្ត្រដូចនេះអាចជួយឱ្យ ក.ស.ព មិនចាំបាច់ជំទាស់ទៅនឹងការយល់ឃើញតាមការសន្មតរបស់ អង្គបុរេជំនុំជម្រះលើគោលការណ៍ស្តីពី *វិមតិសង្ស័យ*។ និយាយម្យ៉ាងទៀត មិនថាឡើយមានគេកំណត់ការការពារដែលបានចែងក្នុងមាត្រា ៣៨ថា មានខ្លឹមសារដូចជាគោលការណ៍ "សច្ចធារណ៍នៃនិរទោស" ក៏ដោយ ឬចាត់ទុកការការពារនេះដោយឈ្មោះផ្សេងយ៉ាងណា ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពី ទំនាក់ទំនងនៃជម្លោះ

១១. ប៉ុន្តែប្រសិនបើយើងពិនិត្យមើលប្រភពនានានៃច្បាប់អន្តរជាតិវិញនោះ វាបញ្ជាក់ច្បាស់ថា មានសំអាងហេតុជាច្រើនក្នុងការអនុវត្តតាមវិធីសាស្ត្ររបស់ អ.ប.ជ ដែលជនជាប់ចោទត្រូវទទួលផលពីគោលការណ៍ "*វិមតិសង្ស័យ*" មិនថាមានការប្រើប្រាស់ពាក្យឡាតាំងណាមួយ ដើម្បីបកស្រាយគោលការណ៍នេះនោះទេ។ សេចក្តីសម្រេចរបស់ អ.ប.ជ ជាការបង្ហាញឱ្យឃើញនូវគោលការណ៍ *ជាប្រយោជន៍ដល់ជនជាប់ចោទ* (*favor rei*)។ យើងអាចនិយាយបានថា គោលការណ៍នោះ មានបំណងបង្ហាញថា ភាពសង្ស័យ និងភាពមិនច្បាស់លាស់ ត្រូវតែធ្វើការសម្រេចក្នុងគោលដៅមួយដែលបានជាប្រយោជន៍ដល់ជនជាប់ចោទ។ អាស្រ័យហេតុនេះ វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (ហើយអ្នកអត្ថាធិប្បាយខ្លះលើកឡើងថា៖ *ជាប្រយោជន៍ដល់ជនជាប់ចោទ* និងពាក្យ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចប្រើជំនួសគ្នាបាន)។

១២. គោលការណ៍ *ជាប្រយោជន៍ដល់ជនជាប់ចោទ* (*favor rei*) ជាគោលការណ៍ដែលបានបង្កើតឡើងក្នុងច្បាប់អន្តរជាតិ[15]។ ដូច្នេះហើយ វាត្រូវបានបង្ហាញឱ្យឃើញក្នុងប្រភពបឋមមួយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលជាលក្ខន្តិកៈក្រុងរ៉ូមនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ លក្ខន្តិកៈក្រុងរ៉ូមចែងក្នុងមាត្រា ២២ (២) ថានិយមន័យនៃបទល្មើសព្រហ្មទណ្ឌ ត្រូវតែបកស្រាយអធិប្បាយឱ្យល្អិត

---

ក៏ដោយ ក៏វាមានបញ្ជាក់យ៉ាងច្បាស់ថា ការការពារ (ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)នេះគឺមានភាពដាច់ខាត និងពាក់ព័ន្ធទៅនឹងករណីនៃវិមតិសង្ស័យទាំងអស់ ទាំងវិមតិសង្ស័យចំពោះកំណត់ទោស ទាំងបញ្ហាច្បាប់។

[15] *មើល* Cassese (Ed) The Oxford Companion to International Criminal Justice (Oxford 2009) ទំព័រ ៤៥០-៤៥១, គោលការណ៍អំពី *ជាប្រយោជន៍ដល់ជនជាប់ចោទ* [...] តម្រូវថា ក្នុងករណីមានការបកស្រាយវិធានដោយមានមតិជំទាស់នេះ ការបកស្រាយនោះត្រូវតែជាប្រយោជន៍ដល់ជនជាប់ចោទ។ [...] អង្គជំនុំជម្រះសាលាដំបូង ICTR បានតម្កល់ទុក គោលការណ៍នេះ នៅក្នុងរឿងក្តី *Akayesu* ទាក់ទងនឹងការបកស្រាយនៃពាក្យ "ការសម្លាប់" នៅក្នុងអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង ICTR St. (សាលក្រម Akayesu) (ICTR-96-4-T) អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ [កថាខណ្ឌ] ៥០០-៥០១)។ អង្គជំនុំជម្រះសាលាដំបូង ICTY បានបញ្ជាក់បន្ថែមគោលការណ៍នេះ នៅក្នុងរឿងក្តី *Krstic* (សាលក្រម Krstic (IT-98-33-T), អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ [កថាខណ្ឌ] ៥០២។ អង្គជំនុំជម្រះសាលាដំបូង [...] ក៏បានគិតដល់បទដ្ឋានដែលគ្រប់គ្រងដល់ការវាយតម្លៃភស្តុតាង ៖ ក្នុងករណីនេះ គោលការណ៍ នេះត្រូវបានគេស្គាល់ថាជា *គោលការណ៍នៃសច្ចធារណ៍នៃនិរទោស*')។ មតិជំទាស់របស់ចៅក្រម Lavergne ក៏អាចចាត់ទុកថាជាការឆ្លុះបញ្ចាំងពីគោលការណ៍ *ជាប្រយោជន៍ដល់ជនជាប់ចោទ*។ មាត្រា ៣៨នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាគឺជាចំណុចបញ្ជាក់មួយទៀត។

ហើយមិនត្រូវពង្រីកវិសាលភាព ដោយការពន្យល់ប្រៀបធៀបឡើយ។ នៅក្នុងករណីមាន *វិមតិសង្ស័យ ការកំណត់និយមន័យនោះ ត្រូវបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងត្រូវរងការស៊ើបអង្កេត ត្រូវនាំយកមកជំនុំជម្រះ ឬត្រូវបានសម្រេចឱ្យមានពិរុទ្ធភាព*[16]។

១៣. បទប្បញ្ញត្តិនេះ បញ្ជាក់យ៉ាងច្បាស់នូវភាពមិនច្បាស់លាស់[17] អំពីអត្ថន័យច្បាប់ និងជាពិសេសទៀតនោះចំពោះនិយមន័យបទឧក្រិដ្ឋមួយ[18]។ ភាពមិនច្បាស់លាស់បែបណានេះ ត្រូវបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងត្រូវរងការស៊ើបអង្កេត ត្រូវនាំយកមកជំនុំជម្រះ ឬត្រូវបានសម្រេចឱ្យមានពិរុទ្ធភាព ដែលជាការបង្ហាញយ៉ាងច្បាស់នូវគោលការណ៍ *ជាប្រយោជន៍ដល់ជនជាប់ចោទ* (*favor rei*)[19]។

១៤. លក្ខន្តិកៈក្រុងរ៉ូម ជាប្រភពផ្លូវការជាងគេមួយក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ដូច្នេះប្រសិនបើមាន

---

[16] លក្ខន្តិកៈក្រុងរ៉ូម, មាត្រា ២២(២) (សេចក្តីបញ្ជាក់បន្ថែម)។

[17] "ភាពស្រពិចស្រពិល" ត្រូវបានកំណត់អត្ថន័យថា ១ក ៖ គុណភាព ឬសភាពនៃភាពមិនច្បាស់លាស់ ជាពិសេសលើអត្ថន័យ (សូមមើលពាក្យ ambiguous) ខ ៖ ពាក្យ ឬខ្លឹមសារដែលអាចយល់បានតាមវិធីមួយ ឬច្រើនយ៉ាង ៖ ពាក្យ ឬខ្លឹមសារមិនច្បាស់លាស់, ២ ៖ ភាពមិនច្បាស់លាស់។ *មើល* ៖ www.merriam-webster.com។

[18] ច្បាស់ណាស់ថា ការជជែកពិភាក្សាយ៉ាងក្តៅគគុកថាតើលក្ខខណ្ឌតម្រូវពីទំនាក់ទំនងមានអត្ថិភាព ឬគ្មាន នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ អាចចាត់ទុកថាជា "ភាពស្រពិចស្រពិល" (តាមខ្លឹមសារនៃមាត្រា ២២(២)នៃលក្ខន្តិកៈក្រុងរ៉ូម ទាក់ទងនឹង "អត្ថន័យ" (ខ្លឹមសារនៃមាត្រា ២២(២)នៃលក្ខន្តិកៈទីក្រុងរ៉ូម)នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងរយៈពេលនោះ។

[19] អង្គហេតុដែលថា មាត្រា ២២នៃលក្ខន្តិកៈក្រុងរ៉ូមហាក់ដូចជាមានទំនាក់ទំនងជាមួយនឹងវិធាននានានៃការបកស្រាយច្បាប់នេះ ជាងការបកស្រាយនៃទស្សនាទានច្បាប់ទំនៀមទម្លាប់អន្តរជាតិ (CIL)មិនត្រូវបានយកមកប្រើឡើយ។ វិធាន និយមន័យ និងទស្សនាទានភាគច្រើនដកស្រង់ចេញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយនឹងអាចបន្តរងឥទ្ធិពលពីទស្សនាទានទាំងនេះ (ដែលបានបង្កើតឡើងជាអចិន្ត្រៃយ៍) នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ (អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ២១(១)(ខ) និង(គ) នៃលក្ខន្តិកៈ ICC។ នៅពេល ICC ត្រូវបានស្នើសុំឱ្យបកស្រាយវិធាន និងទស្សនាទាននៃ CIL នៅពេលសម្រេចលើនិយមន័យនៃឧក្រិដ្ឋកម្ម ការបកស្រាយនោះនឹងត្រូវភ្ជាប់យ៉ាងច្បាស់ជាមួយនឹងបទប្បញ្ញត្តិក្នុងវិធាន ២២(២) ហើយក្នុងករណីនោះ និយមន័យនៃឧក្រិដ្ឋកម្មត្រូវតែបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងត្រូវបានកាត់ទោស។ ជារួម វិធាន ២២(២)បង្កប់សញ្ញាណទូលំទូលាយក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិទំនើបថា ជនជាប់ចោទគួរទទួលបានប្រយោជនពីវិមតិសង្ស័យ ឬ *ជាប្រយោជន៍ដល់ជនជាប់ចោទ*។ នេះគឺជាមូលហេតុដែលត្រូវអនុវត្តសញ្ញាណនេះចំពោះចម្ងល់ទាំងឡាយទាក់ទងនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលគេកាត់សេចក្តីផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលពាក់ព័ន្ធនឹងការកំណត់ឧក្រិដ្ឋកម្មចំពោះការប្រព្រឹត្តមួយចំនួន។

ការស្វែងរកសេចក្តីណែនាំជាវិធាន ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិនោះ[20] អង្គជំនុំជម្រះសាលាដំបូង គួរតែអនុវត្តតាមវិធីសាស្ត្រដែលមានចែងនៅក្នុងមាត្រា ២២ (២) នៃលក្ខន្តិកៈ ហើយធ្វើការបកស្រាយភាពមិនច្បាស់លាស់ណាមួយអំពីនិយមន័យនៃបទឧក្រិដ្ឋមួយ ដែលបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ក្នុងករណីនេះ មានន័យថា អង្គជំនុំជម្រះសាលាដំបូង គួរតែអនុវត្តតាមវិធីសាស្ត្ររបស់ អ.ប.ជ ធ្វើសេចក្តីសន្និដ្ឋានថាមានភាពមិនច្បាស់លាស់ថាតើលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងជាផ្នែកមួយនៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ និងជ្រើសយកការបកស្រាយដែលបានជាប្រយោជន៍ដល់ជនជាប់ចោទ។

## គ. ក.ស.ព លើកឡើងបំផ្លើសអំពីផលវិបាកនៃវិធីសាស្ត្ររបស់ អ.ប.ជ

១៥. នៅក្នុងសារណារបស់ខ្លួន ក.ស.ព កំណត់ខុសចំពោះអ្វីដែល អ.ប.ជ បានអនុវត្តជាក់ស្តែងក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ និងលើកឡើងបំផ្លើសអំពីផលវិបាកអវិជ្ជមានដែលអាចកើតមានដោយសារវិធីសាស្ត្ររបស់ អ.ប.ជ។ ជាការជំទាស់ទៅនឹងការបកស្រាយ និងការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដោយ អ.ប.ជ ក.ស.ព ថ្លែងថាការបកស្រាយរបស់ អ.ប.ជ "មានអត្ថិភាពជាមួយគ្នាមិនងាយស្រួលឡើយទៅនឹងសុភាសិតជាមូលដ្ឋានមួយថា "ចៅក្រមចេះច្បាប់" (*iura novit curia*) និងលើកឡើងថា អ.ប.ជ បាន "ព្រមតាមដោយស្វ័យប្រវត្តិទៅនឹងជនជាប់ចោទ នៅពេលច្បាប់មានការលំបាកក្នុងការធ្វើឱ្យដឹងជាប្រាកដ[21]"។

១៦. ក.ស.ព ខកខានមិនបានទទួលស្គាល់ថា តាមការពិត អ.ប.ជ មិនបានយល់ថា ច្បាប់នេះ "មានការលំបាក"ក្នុងការធ្វើឱ្យដឹងជាប្រាកដឡើយ។ លើសពីនេះទៅទៀត អ.ប.ជ យល់ឃើញថាច្បាប់ដែលពាក់ព័ន្ធ *មិនអាច*ធ្វើឱ្យដឹងជាប្រាកដឡើយ។ ផ្ទុយទៅវិញ *បន្ទាប់ពី*ធ្វើការវិភាគយ៉ាងហ្មត់ចត់លើយុត្តិសាស្ត្រ និងប្រភពដទៃទៀត និងបន្ទាប់ពីអនុវត្តវិធានទូទៅនៃការបកស្រាយបញ្ហាទាំងនេះ *ដែលជាបញ្ហាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ*[22] រួចមក អ.ប.ជ បានធ្វើសេចក្តីសន្និដ្ឋានថា អ.ប.ជ ពិតជាមិនអាចកំណត់បានថា ពេលណាត្រូវផ្តាច់ចេញលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងឡើយ។ យើងគួរកត់សម្គាល់ម្តងទៀតថា អ.ប.ជ ធ្វើសេចក្តីសន្និដ្ឋាននេះដោយបង្ហាញនូវ "ករណី

[20] ជាថ្មីម្តងទៀត ការណ៍នេះមិនបានពិចារណាជាចាំបាច់ដល់ចំណុចដែលថា រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាផ្តល់នូវការការពារមិនសមរម្យ និងមិនច្បាស់លាស់ដល់ជនជាប់ចោទនោះទេ។

[21] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៩។

[22] សេចក្តីសម្រេចរបស់ អ.ប.ជ កថាខណ្ឌ ១៣៧។

មិនមានការអនុវត្តច្បាស់លាស់របស់រដ្ឋនានា និងទស្សនៈច្បាប់ *(opinio juris)* ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលបង្ហាញឲ្យឃើញនូវការផ្តាច់ចេញនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ”[23]។

១៧. អាស្រ័យហេតុនេះ អ.ប.ជ បានបន្តដោះស្រាយភាពមិនច្បាស់លាស់នេះ ជាប្រយោជន៍ដល់ជនជាប់ចោទ។ គ្មានអ្វីដែលមិនសមស្របឡើយក្នុងវិធីសាស្ត្រនេះ។ ផ្ទុយទៅវិញ អ.ប.ជ បានអនុវត្តតាមបទប្បញ្ញត្តិដែលពាក់ព័ន្ធនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា៣៨) និងតាមបទដ្ឋានច្បាប់អន្តរជាតិ។

១៨. លើសពីនេះទៅទៀត ទឡ្ហីករណ៍របស់ ក.ស.ព អំពីផលវិបាកអវិជ្ជមានដែលបានរំពឹងទុកពីការអនុវត្តក្នុងន័យទូលាយចំពោះគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* រួមទាំងការអះអាងរបស់ ក.ស.ព ថាការអនុវត្តន័យទូលាយចំពោះគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នឹង “ធ្វើឲ្យរឹងស្ទូក” នូវការរីកចម្រើននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ, “មានហានិភ័យយ៉ាងធ្ងន់ធ្ងរទៅលើការខូចប្រយោជន៍នៃប្រព័ន្ធច្បាប់អន្តរជាតិ” គឺជាទឡ្ហីករណ៍មិនសមហេតុផលឡើយ។ ក.ស.ព លើកឡើងអំពីវិសាលភាពជាក់លាក់នៃគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ធ្វើជាបញ្ហាទំនាស់រវាងផលប្រយោជន៍របស់ជនជាប់ចោទ និង “តម្រូវការត្រូវរក្សាប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិឲ្យនៅដំណើរការ”។ ក.ស.ព លើកឡើងយ៉ាងដូច្នេះដើម្បីបញ្ជាក់ថា ទៅថ្ងៃអនាគត ប្រព័ន្ធនេះពឹងផ្អែកលើការបកស្រាយតឹងរ៉ឹងលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*។ គ្មានការព្យាករណ៍បែបនេះណាមួយផ្អែកលើតថភាពជាក់ស្តែងនោះឡើយ។

១៩. ជាបឋម យើងគ្រាន់តែត្រូវពិនិត្យមើលផលវិបាកដែលអាចកើតមានដោយសារការអនុវត្តន័យទូលាយនៃគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ក្នុងស្ថានភាពជាក់លាក់នេះ* ដើម្បីធ្វើសេចក្តីសន្និដ្ឋានថា ក.ស.ព លើកឡើងបំផ្លើសអំពីករណីនេះ។ វាមានការលំបាកក្នុងការប្រមើលមើលថាតើ “ការរីកចម្រើននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ” ត្រូវបានគេធ្វើឲ្យរឹងស្ទូក, ហើយជាពិសេស “មានហានិភ័យយ៉ាងធ្ងន់ធ្ងរទៅលើការខូចប្រយោជន៍នៃប្រព័ន្ធច្បាប់អន្តរជាតិ” ដោយរបៀបណា តាមរយៈការអនុវត្តន័យទូលាយនៃគោលការណ៍នេះក្នុងសំណុំរឿងនេះ។ ការណ៍

[23] សេចក្តីសម្រេចរបស់ អ.ប.ជ កថាខណ្ឌ ១៤៤ (បញ្ជាក់បន្ថែម)។

ដែល អ.ប.ជ ទទួលយកនិយមន័យទូលាយនៃ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នៅក្នុងសំអាងហេតុរបស់ខ្លួននាពេលនេះ ក្នុងឆ្នាំ ២០១១ អ.ប.ជ មិនអាចធ្វើសេចក្ដីសន្និដ្ឋានដោយវិជ្ជមានថា លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានផ្ដាច់ចេញរយៈពេល៣៥ឆ្នាំ កន្លងមកហើយនោះ មិនមានឥទ្ធិពលអ្វីទាំងអស់ទៅនឹងការធ្វើឱ្យរឹងស្ដូកនូវ "ការរីកចម្រើន" នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[24]។

២០. ទីពីរ ការលើកឡើងថា ការអនុវត្តន័យទូលាយនៃគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (បណ្ដាលឱ្យមានការអនុវត្តតឹងរ៉ឹងនូវលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ) នឹងមានឥទ្ធិពលក្នុងវិសាលភាពណាមួយលើ "តម្រូវការរក្សានូវប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិដែលអាចដំណើរការ"នោះ មិនសមហេតុផលឡើយ។ មេធាវីការពារក្ដីសូមសន្និដ្ឋានថា វិធីសាស្ត្រដែលជ្រើសរើសដោយ អ.ប.ជ មិនបានធ្វើឱ្យអន្តរាយ ដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ សូម្បីតែបន្តិចបន្តួចឡើយ។ ទោះជាបីយ៉ាងក៏ដោយ អ.ជ.ប *បានលើកស្ទួយ*ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិតាមរយៈ*ការផ្ដល់* ការពារបន្ថែមដល់ជនជាប់ចោទតាមប្រព័ន្ធនេះ។ ការផ្ដល់ការការពារបន្ថែមនេះ ទំនងជាអាចជួយបង្កើនធម្មានុរូប និងការទទួលស្គាល់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ក្នុងពេលអនាគតខាងមុខដ៏វែងឆ្ងាយបាន។

២១. ក្នុងន័យនេះ ផ្ទុយទៅនឹងការលើកឡើងរបស់ ក.ស.ព ការណ៍ដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិ "មិនសូវមានលក្ខណៈត្រង់ដូចប្រភេទច្បាប់ផ្សេងទៀត ហើយវាចាំបាច់ត្រូវស្ថិតក្រោមដំណើរការនីតិវិធីមួយក្នុងការធ្វើសំយោគ និងសម្រេចតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅជាបន្តបន្ទាប់[25]" នោះ មិនមានន័យថា ការអនុវត្តក្នុងន័យទូលាយនៃ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍* នឹងធ្វើឱ្យរឹងស្ដូកការរីកចម្រើននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ ផ្ទុយទៅវិញ តាមការពិតមេធាវីការពារក្ដី សូមសន្និដ្ឋានថា៖ ការអនុវត្តន័យទូលាយនៃគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ជំរុញឱ្យការរីកចម្រើននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទៅវិញទេ។

---

[24] ជាពិសេស នេះគឺជាការពិត នៅពេលពិចារណាថា នៅពេលនេះតាមពិតអ្នកស្រាវជ្រាវ និងអ្នកមានវិជ្ជាជីវៈផ្នែកច្បាប់គ្រប់គ្នាមានការឯកភាពគ្នាថា តម្រូវការពីទំនាក់ទំនងនេះ*បាន* បែងចែកជាផ្នែកនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិបច្ចុប្បន្ន។ ដូចនេះគ្មានការស្រពិចស្រពិលអ្វីទៀតទេ។

[25] សំណើរបស់ ក.ស.ព កថាខណ្ឌ ៣១។

ការប្រកាន់ខ្ជាប់នូវគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ធ្វើឱ្យច្បាប់ទំនៀមទម្លាប់អន្តរជាតិផ្តល់ការពារកាន់តែប្រសើរដល់សិទ្ធិរបស់ជនជាប់ចោទ និងស្របតាមការវិវឌ្ឍន៍ដទៃទៀតក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដូចជាការអនុវត្តតាមនូវមាត្រា ២២ (២) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិជាដើម។ ដូច្នេះហើយ ការរីកចម្រើន*ជាគុណសម្បត្តិ* នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នឹងត្រូវបានជំរុញផងដែរ[26]។ ជាជាងការបង្កើតឱ្យមានឧបសគ្គបង្អាក់ដំណើរការអភិវឌ្ឍន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ វិធីសាស្ត្រនេះ នឹងធានាថាច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានលក្ខណៈស្របគ្នាទាំងស្រុងជាមួយនឹងគោលការណ៍ដែលត្រូវបានទទួលស្គាល់ជាទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

## IV. **សេចក្តីសន្និដ្ឋាន**

២២. អាស្រ័យហេតុនេះ មេធាវីការពារក្តី សូមស្នើអង្គជំនុំជម្រះសាលាដំបូង (ក) ច្រានចោលសំណើរបស់ ក.ស.ព និង (ខ) សម្រេចថា លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងគ្នា មានអត្ថិភាពក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងករណីដែលអង្គជំនុំជម្រះ មានទំនោរយល់ព្រមតាមសំណើរបស់ ក.ស.ព មេធាវីការពារក្តី សូមស្នើឱ្យមានសវនាការដោយផ្ទាល់មាត់លើបញ្ហានេះ ឱ្យមុនពេលចាប់ផ្តើមលើសវនាការលើអង្គសេចក្តី។

---

[26] នៅពេលពិចារណាពីចំណុចមន្ទិលសង្ស័យនៅក្នុង CIL ការងារដំបូង និងសំខាន់បំផុតរបស់តុលាការគឺត្រូវពិនិត្យបញ្ហាបទដ្ឋានដែលចាំបាច់ត្រូវយកមកពិចារណានៅពេលធ្វើការវាយតម្លៃពី CIL នូវ៖ ការអនុវត្តរបស់រដ្ឋ និង *ទស្សនៈច្បាប់*។ នៅពេលតុលាការសន្និដ្ឋានយ៉ាងច្បាស់ថា លក្ខខណ្ឌពីរទាំងពីរនេះត្រូវបានបំពេញហើយនោះ ៖ គ្មានអ្វីមួយដែលអាចបញ្ឈប់តុលាការក្នុងការសន្និដ្ឋានថា វិធានមួយមានគុណសម្បត្តិជា CIL ហើយ ទោះបីវិធាននេះអាចផ្តល់អន្តរាយដល់ជនជាប់ចោទក៏ដោយ។ ផ្ទុយទៅវិញក្នុងស្ថានភាពមានភាពមិនច្បាស់លាស់ធ្ងន់ធ្ងរថា តើមានអត្ថិភាពនៃការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់*ក្នុងកម្រិតសមស្របមួយនោះ (ដល់ CIL) គ្មានមូលហេតុជាគោលការណ៍ណាមួយក្នុងការសម្រេចដោយ*មិន*ផ្តល់ប្រយោជន៍ដល់ជនជាប់ចោទនោះទេ ក្នុងស្ថានភាពដែលជនជាប់ចោទអាចរងព្យសនកម្មដោយសារការចាត់ទុកវិធានណាមួយមានឋានៈជា CIL នោះ។ *សូមមើលជាឧទាហរណ៍* អំពីតម្រូវការសម្រាប់ការអនុវត្តរបស់រដ្ឋច្បាស់លាស់៖ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Vasiljevic,* សំណុំរឿងលេខ IT-98-32-T, "សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ កថាខណ្ឌ ២០៣ ("ដោយពុំមានការបញ្ជាក់ច្បាស់លាស់សម្រាប់ការអនុវត្តរបស់រដ្ឋ ថាតើនិយមន័យនៃបទល្មើស "អំពើហិង្សាដល់ជីវិត និងបុគ្គល" ដែលមានចែងក្នុងលក្ខន្តិកៈដែលអាចស្ថិតក្រោមច្បាប់ទំនៀមទម្លាប់មានន័យយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងមិនយល់ស្របថាបទល្មើសបែបនេះ ដែលបញ្ជាក់ពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលមានអត្ថិភាពក្នុងច្បាប់នោះឡើយ")។

**សហមេធាវីការពារក្តីរបស់លោក នួន ជា**

សុន អរុណ Michiel PESTMAN និង Victor KOPPE